**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** :១៥៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្ដីពីមូលនិធិឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.**_

អនុក្រឹត្យនេះ កំណត់អំពីអត្រាជាភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលត្រូវផ្ទេរប្រចាំឆ្នាំជូនមូលនិធិឃុំ សង្កាត់ និងរូបមន្ត សន្ទស្សន៍នៃការបែងចែកមូលនិធិឃុំ សង្កាត់ ព្រមទាំងកម្មវិធីនៃការផ្ទេរធនធាន និងសាច់ប្រាក់ទៅឱ្យរដ្ឋបាលឃុំ សង្កាត់ សម្រាប់ថិរវេលា ០៥ (ប្រាំ)ឆ្នាំ ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨។

**មាត្រា២.**_

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្ដប់លើរដ្ឋបាលឃុំ សង្កាត់ទាំងអស់ទូទាំងប្រទេស។

## ជំពូកទី២

## ប្រភពធនធាន

**មាត្រា៣.**_

កម្រិតនៃការផ្ទេរធនធានពីថវិការដ្ឋទៅក្នុងគណនីមូលនិធិឃុំ សង្កាត់ ត្រូវកំណត់សម្រាប់ថិរវេលា ០៥ (ប្រាំ)ឆ្នាំ ដោយកំណត់ជាភាគរយ នៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដូចខាងក្រោម÷

- ឆ្នាំថវិកា២០២៤: ចំនួន ៣,៥ភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលបានអនុម័តឆ្នាំ២០២៣
- ឆ្នាំថវិកា២០២៥: ចំនួន ៣,៥ភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលបានអនុម័តឆ្នាំ២០២៤
- ឆ្នាំថវិកា២០២៦ : ចំនួន ៣,៥ភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលបានអនុម័តឆ្នាំ២០២៥
- ឆ្នាំថវិកា២០២៧: ចំនួន ៣,៥ភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលបានអនុម័តឆ្នាំ២០២៦
- ឆ្នាំថវិកា២០២៨: ចំនួន ៣,៥ភាគរយនៃចំណូលចរន្តថវិកាថ្នាក់ជាតិ ដែលបានអនុម័តឆ្នាំ២០២៧។

## ជំពូកទី៣

## ការបែងចែក ការផ្ទេរ និងការប្រើប្រាស់ធនធានមូលនិធិឃុំ សង្កាត់

**មាត្រា៤.-**

ធនធានមូលនិធិឃុំ សង្កាត់ ត្រូវបែកចេញជាបីសមាសភាគដូចខាងក្រោម÷

- សមាសភាគរដ្ឋបាលទូទៅ
- សមាសភាគសេវាសង្គម និងអនាម័យបរិស្ថាន និង
- សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន។

ការបែងចែកធនធានមូលនិធិឃុំ សង្កាត់សរុបប្រចាំឆ្នាំនីមួយៗ ត្រូវបានកំណត់ទៅតាមលំដាប់លំដោយនៃអាទិភាពចំណាយដូចខាងក្រោម÷

ទី១- ចំណាយសរុបសម្រាប់ប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីភូមិ និងបុគ្គលិកក្រៅក្របខណ្ឌរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់

ទី២- ចំណាយសរុបសម្រាប់ប្រតិបត្តិការរដ្ឋបាល មិនឱ្យលើសពី១៧ភាគរយនៃធនធានមូលនិធិឃុំ សង្កាត់សរុប *ដក* ចំណាយសរុបសម្រាប់ប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីភូមិ និងបុគ្គលិកក្រៅក្របខណ្ឌរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់

ទី៣- ចំណាយសរុបសម្រាប់សមាសភាគសេវាសង្គម និងអនាម័យបរិស្ថាន ត្រូវកំណត់ជាភាគរយដូចខាងក្រោម÷

- ឆ្នាំថវិកា២០២៤: ចំនួន១៣ភាគរយនៃធនធានមូលនិធិឃុំ សង្កាត់សរុប *ដក* ចំណាយសរុបសម្រាប់ប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីភូមិ និងបុគ្គលិកក្រៅក្របខណ្ឌរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់

- ឆ្នាំថវិកា២០២៥: ចំនួន ១៨ភាគរយនៃធនធានមូលនិធិឃុំ សង្កាត់សរុប *ដក* ចំណាយសរុបសម្រាប់ប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីភូមិ និងបុគ្គលិកក្រៅក្របខណ្ឌរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់
- ឆ្នាំថវិកា២០២៦: ចំនួន ២២ភាគរយនៃធនធានមូលនិធិឃុំ សង្កាត់សរុប *ដក* ចំណាយសរុបសម្រាប់ប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីភូមិ និងបុគ្គលិកក្រៅក្របខណ្ឌរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់
- ឆ្នាំថវិកា២០២៧: ចំនួន ២៦ភាគរយនៃធនធានមូលនិធិឃុំ សង្កាត់សរុប *ដក* ចំណាយសរុបសម្រាប់ប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីភូមិ និងបុគ្គលិកក្រៅក្របខណ្ឌរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់
- ឆ្នាំថវិកា២០២៨: ចំនួន ៣១ភាគរយនៃធនធានមូលនិធិឃុំ សង្កាត់សរុប *ដក* ចំណាយសរុបសម្រាប់ប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីភូមិ និងបុគ្គលិកក្រៅក្របខណ្ឌរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់។

មុខសញ្ញាចំណាយសម្រាប់សេវាសង្គម និងអនាម័យបរិស្ថាន ត្រូវកំណត់ដោយសេចក្តីណែនាំរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។

ទី៤- ចំណាយសរុបសម្រាប់សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ស្មើនឹងធនធានមូលនិធិឃុំ សង្កាត់សរុប *ដក* ចំណាយសរុបសម្រាប់ប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីភូមិ និងបុគ្គលិកក្រៅក្របខណ្ឌរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់ ចំណាយសរុបសម្រាប់ប្រតិបត្តិការរដ្ឋបាល និងចំណាយសរុបសម្រាប់សមាសភាគសេវាសង្គម និងអនាម័យបរិស្ថាន។

**មាត្រា៥._**

ចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាល ចំណាយសម្រាប់សមាសភាគសេវាសង្គម និងអនាម័យបរិស្ថាន និងចំណាយសម្រាប់សមាសភាគអភិវឌ្ឍន៍មូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានវិភាជទៅឱ្យរដ្ឋបាលឃុំ សង្កាត់នីមួយៗតាមការគណនាដោយផ្អែកលើរូបមន្ត និងសន្ទស្សន៍ដូចខាងក្រោម÷

**ក- ចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាល÷**

- ចំនួន ៤០ភាគរយ ជាចំណែកស្មើគ្នាត្រូវបានបែងចែកក្នុងចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលឃុំ សង្កាត់នីមួយៗ និង

- ចំនួន ៦០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ។

**ខ- ចំណាយសម្រាប់សមាសភាគសេវាសង្គម និងអនាម័យបរិស្ថាន÷**

- ចំនួន ៣០ភាគរយ ជាចំណែកស្មើគ្នាត្រូវបានបែងចែកក្នុងចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលឃុំ សង្កាត់នីមួយៗ
- ចំនួន ២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនប្រជាពលរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ និង
- ចំនួន ៥០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ។

**គ- ចំណាយសម្រាប់សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន÷**

- ចំនួន ៣០ភាគរយ ជាចំណែកស្មើគ្នាត្រូវបានបែងចែកក្នុងចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលឃុំ សង្កាត់នីមួយៗ
- ចំនួន ៣០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនប្រជាពលរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់ នីមួយៗដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ
- ចំនួន ៣០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ និង
- ចំនួន ១០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនភូមិរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងមហាផ្ទៃ។

**មាត្រា៦._**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបោះផ្សាយអាណត្តិឧបត្ថម្ភធនជូនមូលនិធិឃុំ សង្កាត់ជា ០៤(បួន) លើក សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំតាមកម្មវិធីដូចខាងក្រោម÷

- លើកទី១ : ផ្ទេរ ២៥ភាគរយនៃធនធានមូលនិធិសរុបនៅដើមត្រីមាសទី១
- លើកទី២ : ផ្ទេរ ២៥ភាគរយនៃធនធានមូលនិធិសរុបនៅដើមត្រីមាសទី២
- លើកទី៣ : ផ្ទេរ ៤០ភាគរយនៃធនធានមូលនិធិសរុបនៅដើមត្រីមាសទី៣
- លើកទី៤ : ផ្ទេរ ១០ភាគរយនៃធនធានមូលនិធិសរុបនៅដើមត្រីមាសទី៤។

**មាត្រា៧.-**

រដ្ឋបាលឃុំ សង្កាត់អាចប្រើប្រាស់ធនធានដែលផ្ទេរពីមូលនិធិឃុំ សង្កាត់ ដើម្បីផ្តល់ហិរញ្ញប្បទានដល់ចំណាយសមាសភាគណាមួយបាន លុះត្រាតែចំណាយទាំងនោះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងថវិការបស់រដ្ឋបាលឃុំ សង្កាត់ ដែលបានអនុម័តដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងមិនផ្ទុយនឹងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិដែលមានការពាក់ព័ន្ធជាធរមាន។

**មាត្រា៨.-**

ការអនុវត្តថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំ សង្កាត់ ចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។ ចំពោះគម្រោង ឬកម្មវិធីដែលអនុវត្តមិនទាន់ចប់នៅក្នុងឆ្នាំថវិកា ត្រូវដាក់បញ្ចូលដើម្បីបន្តអនុវត្តនៅក្នុងគម្រោងថវិកាឆ្នាំបន្ទាប់ ដែលការគ្រោងចំណាយនេះស្ថិតនៅក្នុងកម្មវិធីវិនិយោគប្រចាំឆ្នាំ ដែលក្រុមប្រឹក្សាឃុំ សង្កាត់បានពិនិត្យ និងអនុម័តចុងក្រោយបំផុត។

កម្មវិធីវិនិយោគប្រចាំឆ្នាំ ដែលទទួលបានហិរញ្ញប្បទានគាំទ្រក្រោយពេលដែលមានគម្រោងថវិកាត្រូវបានអនុម័ត គឺជាកម្មវត្ថុនៃការកែសម្រួលគម្រោងថវិកាទៅតាមនីតិវិធីដូចគ្នាទៅនឹងការរៀបចំ និងអនុម័តថវិកាដំបូង។

**មាត្រា៩.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវគណនា និងជូនដំណឹងជាផ្លូវការនៅមុនដំណាច់ខែមិថុនានៃឆ្នាំថវិកាអំពីទំហំធនធានវិភាជន៍ដែលរដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវទទួលបានសម្រាប់ឆ្នាំបន្ទាប់ក្នុងក្របខ័ណ្ឌនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា១០.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិចាត់ចែងធ្វើការផ្ទៀងផ្ទាត់ដោយធ្វើអធិការកិច្ចហិរញ្ញវត្ថុ ឬការត្រួតពិនិត្យហិរញ្ញវត្ថុ តាមការចាំបាច់ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ និងបទប្បញ្ញត្តិដែលមានការពាក់ព័ន្ធជាធរមាន។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**មាត្រា១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក អភិបាលនៃគណៈអភិបាលក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃចន្ទ ៨រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល</u>** ÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ